# មេធាវីអន្តរជាតិនឹងដាក់ករណីសម្លាប់លោក កែម ឡី ទៅ ICC

Thu, 8 September 2016

ឡាយ សាមានភ្នំពេញ ប៉ុស្តិ៍

ពិធីដង្ហែរសពលោក កែម ឡី កាលពីខែកក្កដា។ ហេង ជីវ័ន

ភ្នំពេញៈ លោក Richard Rogers មេធាវីជនជាតិអង់គ្លេសដែលគេស្គាល់ដោយសារតែរូបលោកបានស្នើសុំតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ឲ្យធ្វើការស៊ើបអង្កេត«ឥស្សរជនកាន់អំណាច» របស់ប្រទេសកម្ពុជាបានថ្លែងថាលោកនឹងស្នើសុំឲ្យតុលាការពង្រីកករណីនោះដើម្បីបញ្ចូលករណីឃាតកម្មកាលពីថ្ងៃទី ១០ ខែកក្កដាលើអ្នកវិភាគនយោបាយលោកបណ្ឌិត កែម ឡី មួយករណីទៀតខណៈដែលសំណុំរឿងនេះស្ងប់ស្ងាត់។

លោក Rogers បន្តថា៖ «យើងមិនធ្វើការចោទប្រកាន់លើនរណាទេប៉ុន្តែវាស័ក្តិសមស្ថិតក្នុងចំណាត់ថ្នាក់ឃាតកម្មហេតុផលនយោបាយដូច្នេះវាពាក់ព័ន្ធនឹងករណីតុលាការព្រហ្មទណ្ឌអន្តរជាតិ»។

លោកសង្ឃឹមថានឹងដាក់សេចក្តីសង្ខេបថ្មីមួយទៅតុលាការនៅខែតុលាខាងមុខនេះ។

ពាក្យបណ្តឹងដែលត្រូវបានដាក់កាលពីឆ្នាំ ២០១៤ បានស្នើតុលាការព្រហ្មទណ្ឌអន្តរជាតិស៊ើបអង្កេតករណីឃាតកម្មលើអ្នកប្រឆាំង និងការរំលោភយកដីធ្លីជាប្រព័ន្ធដែលប្រព្រឹត្តឡើងដោយជនកាន់អំណាចរបស់ប្រទេសនេះ។ វាមិនច្បាស់ទេថាតើតុលាការនឹងសម្រេចបន្ថែមករណីឃាតកម្មលោក កែម ឡី ចូលទៅក្នុងបញ្ជីពិនិត្យបឋមរបស់ខ្លួនឬអត់នោះដែលវាជាជំហានសំខាន់ទីមួយសម្រាប់ចាប់ផ្តើមការស៊ើបអង្កេតរបស់ ICC។

ទោះយ៉ាងណាក្តីលោក Rogers ថ្លែងថាលោកបានទទួលការជូនដំណឹងក្រៅផ្លូវការពីតុលាការថាសេចក្តីសម្រេចអាចនឹងធ្វើឡើងត្រឹមចុងឆ្នាំនេះ។

ប៉ុន្តែក្រុមអ្នកជំនាញច្បាប់បានថ្លែងថាវានឹងពិបាកបញ្ចូលករណីនេះទៅក្នុងបញ្ជី។ William Schabas ដែលជាអ្នកជំនាញស្តីពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិថ្លែងថា៖ «ប្រសិនបើព្រះរាជអាជ្ញាគិតថាករណីនេះធ្ងន់ធ្ងរគ្រប់គ្រាន់នោះអាចនឹងបញ្ចូលក្នុងបញ្ជី»។ «ប៉ុន្តែវាជាការងារធំមួយ ដែលត្រូវកំណត់ថា ជាករណីធ្ងន់ធ្ងរ»។

ទន្ទឹមនេះអ្នកនាំពាក្យរដ្ឋាភិបាលលោក ផៃ ស៊ីផាន ថ្លែងថាលោកមិនយកចិត្តទុកដាក់ចំពោះករណីនេះទេ។ លោកបញ្ជាក់ថា៖ «ខ្ញុំគិតថាពួកគេមិនអាចទម្លាក់កំហុសលើរដ្ឋាភិបាលចំពោះករណីឃាតកម្មនេះទេ»។

ប្អូនប្រុសលោកបណ្ឌិត កែម ឡី គឺលោក កែម រិទ្ធីសិទ្ធ សង្ឃឹមថាតុលាការអន្តរជាតិនឹងអាចជួយស្វែងរកយុត្តិធម៌ជូនក្រុមគ្រួសាររបស់លោកខណៈលោកអស់ជំនឿលើប្រព័ន្ធយុត្តិធម៌ក៏ដូចជាអាជ្ញាធរនៅកម្ពុជា។

លោកថា៖ «ប្រហែលអាជ្ញាធរខ្មែរយើងគេមិនចង់ធ្វើបើធ្វើមិនពិបាកទេព្រោះខ្លាចពាក់ព័ន្ធនឹងអ្នកនយោបាយតែបើខាងមេធាវីអន្តរជាតិគេធ្វើការដោយយុត្តិធម៌ហើយសង្ឃឹមច្រើន»។ យ៉ាងណាក៏ដោយលោកបញ្ជាក់ថាក្រោយបុណ្យ ១០០ ថ្ងៃលោកបណ្ឌិត កែម ឡី រួចរាល់ខាងក្រុមគ្រួសារនឹងដាក់ពាក្យប្តឹងទៅក្រសួងមហាផ្ទៃឱ្យស្រាវជ្រាវរកអ្នកនៅពីក្រោយខ្នងបន្ថែមទៀត និងទាមទារឲ្យបញ្ចេញវីដេអូពាក់ព័ន្ធនឹងឃាតកម្មនេះ។

នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សហៅកាត់ថាសង់ត្រាល់លោក មឿន តុលា មើលឃើញថាអាជ្ញាធរកម្ពុជាហាក់បីដូចជាមានចេតនាមិនចង់ស្វែងរកយុត្តិធម៌ពិតជូនក្រុមគ្រួសារលោក កែម ឡី ឡើយទើបធ្វើឱ្យមេធាវីអន្តរជាតិសម្រេចដាក់ពាក្យប្ដឹងទៅតុលាការអន្តរជាតិ។

លោកថា៖ «នៅពេលដែលយើងមិនមានជំនឿលើប្រព័ន្ធតុលាការក្នុងស្រុកយើងមានតែជម្រើសប្រព័ន្ធតុលាការអន្តរជាតិនោះទេគឺជារឿងចាំបាច់ព្រោះកន្លងមកគេបានដាក់ពាក្យទៅតុលាការអន្តរជាតិពីការជម្លៀសពលរដ្ឋដោយបង្ខំអ៊ីចឹងករណីរឿង កែម ឡី គឺជាភ័ស្តុតាងមួយទៀតបង្ហាញពីការដឹកនាំរបស់រដ្ឋាភិបាលរំលោភទៅលើសិទ្ធិមនុស្ស និងប្រឆាំងនឹងមនុស្សជាតិ»។

លោកថា បើអាជ្ញាធរពិតជាចង់រកយុត្តិធម៌ជូនលោក កែម ឡី គួរតែយកវីដេអូដែលនៅជុំវិញនោះមកផ្គុំគ្នានោះនឹងរកឃើញឃាតករពិតប្រាកដ។

លោកថា៖ «ដើម្បីរកឱ្យដឹងថាតើអ្នកណាឃាតករពិតប្រាកដគឺស្រួលទេព្រោះយើងមានវីដេអូជួបសម្លាប់រត់តាមផ្លូវហ្នឹងហើយវីដេអូនេះមានការសង្ស័យច្រើនមួយទៀតយើងយកវីដេអូនោះមកផ្គុំគ្នាជាមួយវីដេអូក្នុងស្តារម៉ាតកាល់តិចអ៊ីចឹងបើយកវីដេអូមកផ្គុំគ្នានឹងមើលឃើញថាតើអ្នកណាឃាតករពិតប្រាកដហើយអ្នកណាខ្លះរួមដៃជាមួយឃាតករហើយឃាតករជិះឡាន ឬជិះម៉ូតូមក»។

បើតាមលោក មឿន តុលា នៅពេលតុលាការអន្តរជាតិរកឃើញថាមេដឹកនាំរបស់កម្ពុជាពិតជាបានរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ឬប្រឆាំងមនុស្សជាតិគេនឹងអាចដាក់ទណ្ឌកម្មហើយអន្តរជាតិនឹងមិនមកធ្វើជំនួញនៅក្នុងប្រទេសកម្ពុជាឡើយ។

ខណៈដែលសំណុំរឿងបាញ់សម្លាប់លោក កែម ឡី ស្ងប់ស្ងាត់ភរិយា និងកូនៗទាំង ៤ រូបរបស់អ្នកវិភាគល្បីឈ្មោះរូបនេះបានភៀសខ្លួនទៅក្រៅប្រទេសហើយទទួលបានសិទ្ធិជាជនភៀសខ្លួនពីឧត្តមស្នងការអង្គការសហប្រជាជាតិនៅក្រុងបាងកក៕ PS

Cristina Maza